# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

<u>សេចក្តីប្រកាសព័ត៌មាន</u>

# ការប្រកាសបើកកម្មវិធីអាហារូបករណ៍ទៅសិក្សានៅប្រទេសអូស្ត្រាលី សំរាប់ឆ្នាំ២០១៧

នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៦ នៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់ ភារៈធារីស្ថានទូតអូស្ត្រាលី លោក **សាយម៉ុន ហ្វៀលឡូវស៍** និង ឯកឧត្តម **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នឹងរួមគ្នាបើកជាផ្លូវការនូវកម្មវិធីអាហារូបករណ៍ ដើម្បីបន្តការសិក្សានៅប្រទេសអូស្ត្រាលីក្នុងឆ្នាំ ២០១៧។

អាហារូបករណ៍អូស្ត្រាលី គឺជាអាហារូបករណ៍ ដែលមានកិត្យានុភាពលក្ខណៈអន្តរជាតិ ផ្តល់ដោយ រដ្ឋាភិបាលអូស្ត្រាលី សំរាប់អ្នកដឹកនាំពិភពលោកជំនាន់ក្រោយ។

លោក ហ្វៀលឡូវស៍ មានប្រសាសន៍ថា៖ " នេះគឺជាឱកាសដ៏ប្រពៃមួយ សំរាប់ប្រជាជនកម្ពុជា ដែលចង់ទៅសិក្សាថ្នាក់ក្រោយឧត្តម នៅសកលវិទ្យាល័យលំដាប់ថ្នាក់ពិភពលោក។ ខ្ញុំសូមលើកទឹកចិត្តដល់អ្នកដែលចាប់អារម្មណ៍ អោយចូលរួមដាក់ពាក្យ ដើម្បីទទួលបានអាហារូបករណ៍អូស្ត្រាលី។"

អាហារូបករណ៍អូស្ត្រាលីសំរាប់ឆ្នាំ២០១៧ បើកទទួលពាក្យចាប់ពីពេលនេះ រហូតដល់ ថ្ងៃ ៣០ មេសា ឆ្នាំ២០១៦។ សូមអញ្ជើញ បេក្ខជនដែលចង់សិក្សាលើគ្រប់ផ្នែកទាំងអស់ ចូលរួមដាក់ពាក្យ។ យើងសូមលើកទឹកចិត្តជាពិសេស ដល់បេក្ខជនដែលចង់សិក្សាផ្នែក ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម សុខាភិបាល គ្រប់គ្រងវិស័យអប់រំ ពាណិជ្ជកម្ម និងមុខវិជ្ជាទាំងឡាយណាដែលអាចចូលរួមកាត់បន្ថយអំពើហិង្សាលើស្ត្រី ចូលរួមដាក់ពាក្យសំរាប់អាហារូបករណ៍នេះ។

នៅក្នុងកម្មវិធីនោះផងដែរ លោក ហ្វៀលឡូវស៍ និង ឯកឧត្តម ជា សុផារ៉ា នឹងធ្វើការស្វាគមន៍នូវការវិលត្រលប់មកកាន់មាតុភូមិវិញ នៃនិស្សិតអាហារូបករណ៍អូស្ត្រាលីចំនួន៥២រូប ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីអូស្ត្រាលីកាលពីឆ្នាំ២០១៥។

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

ឯកឧត្តម ជា សុផារ៉ា មានប្រសាសន៍ថា៖ " និស្សិតដែលបានបញ្ចប់ការសិក្សាហើយត្រលប់មកវិញនៅពេលនេះ បាននាំនាំមកជាមួយនូវគំនិតថ្មីៗ ព្រមទាំងចំនេះដឹងនិង សមត្ថភាព ដើម្បីចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ "

កម្មវិធីអាហារូបករណ៍អូស្ត្រាលី បើកទទួលពាក្យពីបេក្ខជនទាំងអស់ដែលមកពី ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងវិស័យឯកជនផងដែរ។ រដ្ឋាភិបាលអូស្ត្រាលីបានប្តេជ្ញាចិត្តក្នុងការផ្តល់ឱកាសជូនដល់មនុស្សគ្រប់គ្នា ហើយយើងសូមលើកទឹកចិត្តជាពិសេសដល់ ស្ត្រី ជនពិការ និងបេក្ខជនដែលមកពីតាមបណ្តាខេត្តនានា ក្នុងការដាក់ពាក្យ ។


ព័ត៌មានបន្ថែមអំពីអាហារូបករណ៍អូស្ត្រាលី សូមចូលទៅវេបសាយ www.australiaawards.gov.au

ទំនាក់ទំនងព័ត៌មាន៖ លោកស្រី **រូត ស្ទីវ៉េត** អនុប្រធានបេសកកម្ម ស្ថានទូតអូស្ត្រាលី

ទូរស័ព្ទលេខ ០២៣ ២១៣ ៤៧០


ភ្នំពេញថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៦